ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

**សារជូនពរ**
**សូមគោរពជូន**
**ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
**ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៧១ ឈានចូល ៧២ឆ្នាំ**

***ឯកឧត្តម ជាទីគោរព!***

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយក្តីរំភើបរីករាយជាទីបំផុត ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៧១ ឈានចូល ៧២ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ៧កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **ឯកឧត្តម** សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងកាយមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍ ប្រទេសជាតិឱ្យកាន់តែរីកចម្រើនរុងរឿង។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពកោតសរសើរដោយស្មោះស្ម័គ្រចំពោះ **ឯកឧត្តម** ដែលជាប្រមុខការទូតដ៏ឆ្នើមរបស់កម្ពុជា ពោរពេញទៅដោយសមត្ថភាព ឧត្តមភាព ភាពប៉ិនប្រសប់ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ទន្ទឹមគ្នានេះ ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តម** នៅលើវិស័យការទូតក្នុងរយៈពេលកន្លងមក បានបើកឱកាសឱ្យកម្ពុជាមានទំនាក់ទំនងការបរទេស និងកិច្ចសហប្រតិបត្តិការល្អលើឆាកអន្តរជាតិ ព្រមទាំងពង្រឹងបាននូវឧត្តមភាព និងកិត្យានុភាពជាតិ អាចរក្សាបាននូវឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមលើកដៃបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះព្រំនូវសព្ទសាធុការពរជ័យ ជូន **ឯកឧត្តម** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** ទទួលនូវការគោរពអំពីខ្ញុំបាទ។

ថ្ងៃព្រហ ១៣កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២៥
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

វិថីហ្សកនីមីស្រ្ត សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៨៤ email: generalsec@mod.gov.kh